**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៤២៤៧ **អយក.ហវ**

ថ្ងៃ ច័ន្ទ ១២រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០២០

**ជម្រាបមក**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានអង្គភាពថវិកា រដ្ឋបាលកណ្តាល**

**- លោក លោកស្រី ជាប្រធានអង្គភាពថវិកា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** សំណើសុំពន្លឿនការទូទាត់ថវិកាកម្មវិធីពេញលេញរបស់អង្គភាពនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអនុវត្តថវិកាក្នុងឆ្នាំ២០២០។

**យោង ៖** -ប្រកាសអន្តរក្រសួងលេខ០៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា

-លិខិតលេខ៧៦៣ អយក.ហវ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានជ្រាបថា៖ ចាប់តាំងពីឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ ដោយមានអង្គភាពថវិកាចំនួន៦៣(រដ្ឋបាលកណ្តាលចំនួន៣៨និងរាជធានី-ខេត្តចំនួន២៥) និងកម្មវិធីចំនួន៥ ព្រមទាំងវិមជ្ឈការហិរញ្ញវត្ថុជូនអង្គភាពថវិកាក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការទទួលខុសត្រូវ និងលើកកម្ពស់តម្លាភាព គណនេយ្យភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រកបដោយភាពជាម្ចាស់ ហើយស្របតាមផែនការសកម្មភាពនិងទាន់ពេលវេលាដែលបានគ្រោងទុក។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចូលរួមអភិវឌ្ឍន៍សមត្ថភាពបន្ថែមជូនដល់ថ្នាក់ដឹកនាំនិងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យយល់កាន់តែស៊ីជម្រៅ ស្តីពីនីតិវិធីនៃការអនុវត្តថវិកានិងបង្កើតប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុជូនដល់អង្គភាព ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការពិនិត្យតាមដាននិងវាយតម្លៃ។ ដោយឡែក ការអនុវត្តថវិកាគិតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០របស់ក្រសួងសរុបចំនួន៥៨.៧% ធៀបនឹងឥណទានកែតម្រូវ ក្នុងនោះរដ្ឋបាលកណ្តាលចំនួន២៣.៧% និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត៦២.៧%។ បើពិនិត្យតាមស្ថានភាពជាក់ស្តែងនៃការអនុវត្តថវិកាឆ្នាំ២០២០ មិនទាន់ឆ្លើយតបនឹងចំណុចដៅ ដោយមានអត្រាទូទាត់ទាបជាងឆ្នាំ២០១៩ កន្លងមក ជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ផែនការសកម្មភាពនិងសូចនាករគោលដៅរបស់ក្រសួង។ ក្នុងន័យនេះ ដើម្បីពង្រឹងការអនុវត្តថវិកាឆ្នាំ២០២០ ឱ្យប្រព្រឹត្តទៅដោយរលូននិងស្របតាមក្របខណ្ឌច្បាប់គតិយុត្ត ក្រសួងស្នើសុំកំណត់៖



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

១-ប្រធានកម្មវិធីនិងប្រធានអង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្ដាលនិងមន្ទីរអប់រំ យុវជន និងកីឡា ក្រោមឱវាទក្រសួង ត្រូវចូលរួមជំរុញនិងពន្លឿនរាល់ប្រតិបត្តិការនៃការអនុវត្តថវិកាឱ្យស្របតាមក្របខណ្ឌពេលវេលានិងផែនការសកម្មភាព ហើយស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននិងសារាចរណែនាំ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកានិងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាកំហិត ។

២-ការបោះផ្សាយអាណត្តិបើកប្រាក់និង/ឬអាណត្តិនិយ័តកម្មគ្រប់ប្រភេទចុងក្រោយបង្អស់ ដែលបានចុះហត្ថលេខាអាណាប័កដើមខ្សែ ត្រូវបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុយ៉ាងយូរត្រឹមសប្តាហ៍ទី២ ខែធ្នូ ឆ្នាំ២០២០ ដើម្បីឆ្លងការឯកភាពក្នុងប្រព័ន្ធព័ត៌មានវិទ្យា(FMIS) រីឯអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិក៏ត្រូវបញ្ជូនយ៉ាងយូរត្រឹមដើមសប្តាហ៍ទី៣ ខែធ្នូ ឆ្នាំ២០២០ ដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអប់រំ យុវជន និងកីឡា។ ដោយឡែក ក្នុងករណីអង្គភាពថវិកាបោះផ្សាយអាណត្តិបើកប្រាក់និង/ឬអាណត្តិនិយ័តកម្មមិនមានឯកសារគតិយុត្ត ភ្ជាប់មកជាមួយគ្រប់គ្រាន់ ត្រឹមត្រូវ និងច្បាស់លាស់ នោះក្រសួងនឹងមិនឯកភាពផ្តល់ជូនតាមសំណើទេ សម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៣-ក្នុងករណីការបោះផ្សាយអាណត្តិបើកប្រាក់និង/ឬអាណត្តិនិយ័តកម្ម ចុងក្រោយបង្អស់របស់អង្គភាពថវិកា មិនទាន់ពេលដូចនឹងចំណុចទី២ខាងលើ ក្រសួងនឹងមិនអនុញ្ញាតឲ្យដំណើរការក្នុងប្រព័ន្ធព័ត៌មានវិទ្យា(FMIS) ដោយតម្រូវឲ្យប្រើប្រាស់ឥណទានថវិកានៅឆ្នាំបន្ទាប់គឺឆ្នាំ(N+1)សម្រាប់ទូទាត់ការចំណាយនេះសម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៤-គ្រប់ប្រធានអង្គភាព ត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវភាពជាម្ចាស់ក្នុងការពិនិត្យតាមដាននិងចូលរួមជំរុញយ៉ាងសកម្មនូវការអនុវត្តថវិកាឱ្យទាន់ពេលវេលា ដើម្បីធានាស្ថិរភាពនិងចីរភាពនៃតុល្យភាពចំណាយក្នុងការលើកកម្ពស់សុខុមាលភាពការងាររបស់អង្គភាពសាមី។

៥-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងក្នុងករណីមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តថវិកា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់និងទាន់ពេលវេលា តាមការគួរ។

**សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- គ្រប់អគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ .នា. ហិរញ្ញវត្ថុ